# គុណនិងទោស

# របស់

# ភោគៈ

ព្រះសាសនមុនី កិម-ត្រូវ

វត្តឧណ្ណាលោម ក្រុងភ្នំពេញ

ដកស្រង់ចេញពីទស្សនាវដ្ដីពន្លឺពុទ្ធចក្រ

លេខ៧ ខែកក្កដា-សីហា-កញ្ញា ព.ស.២៥០៥ គ.ស.១៩៦២

***

# គុណនិងទោស

# របស់

# ភោគៈ

## ព្រះសាសនមុនី កិម-ត្រូ

### វត្តឧណ្ណាលោម ក្រុងភ្នំពេញ

### ដកស្រង់ចេញពីទស្សនាវដ្ដីពន្លឺពុទ្ធចក្រ

### លេខ១៧ ខែកក្កដា-សីហា-កញ្ញា ព.ស.២៥០៥ គ.ស.១៩៦២

***

នមត្ថុ រតនត្តយស្ស

សូមសម្ដែងអំពីគុណនិងទោសរបស់ ភោគៈ ដោយសង្ខេបដូចមានសេចក្ដីតទៅនេះ ៖

មនុស្សទាំងឡាយដែលកើតមកក្នុងលោក សុទ្ធតែមានបំណងតែមួយដូចគ្នា គឺត្រូវការចង់បាន ភោគៈ ហើយស្វែងរក ភោគៈ ដើម្បីញ៉ាំងជីវភាពរបស់ខ្លួនឲ្យបានថ្លៃថ្នូរ។ ដោយអំណាចនៃការស្វែងរកនោះឯងគង់តែបានជួបប្រទះខ្លះនឹងគំនរ ភោគៈ នោះ ទោះបីតិច ទោះបីច្រើន។

ភោគៈ ដែលបានមកនៅក្នុងកណ្ដាប់ដៃនៃបុគ្គលណា អាចញ៉ាំងបុគ្គលនោះ ឲ្យបានសម្រេចតាមសេចក្ដីប្រាថ្នាគ្រប់ជំពូកក្នុងពេលបច្ចុប្បន្ននេះ ក៏

ពិតមែន ប៉ុន្តែភោគនោះនាំឲ្យទៅជាគុណក៏មាន នាំឲ្យទៅជាទោសក៏មាន ប្រៀបដូចដុំភ្លើង បុគ្គលអ្នកមានប្រាជ្ញា យកដុំភ្លើងនោះមកប្រើការឲ្យសម្រេចទៅជាគុណប្រយោជន៍ច្រើនយ៉ាងគឺ ចម្អិនអាហារ អុជបំភ្លឺក្នុងទីងងឹតជាដើម បានដោយស្រួល ឯបុគ្គលអ្នកឥតប្រាជ្ញា យកដុំភ្លើងនោះមកប្រើការ ត្រឡប់ទៅជាបានទោសវិញ គឺរលាកដៃ រលាកជើងឬឆេះរបស់ប្រើប្រាស់ផ្សេងៗ មានផ្ទះសម្បែងជាដើម ព្រោះតែមិនចេះ មិនប៉ិនប្រសប់ប្រើភ្លើងយ៉ាងណា ភោគៈ ដែលនៅក្នុងកណ្ដាប់ដៃនៃបុគ្គលអ្នកប្រាជ្ញានិងបុគ្គលអ្នកឥតប្រាជ្ញា រមែងឲ្យគុណនិងទោស ដល់ម្ចាស់អ្នកប្រើប្រាស់វិញ ក៏ដូច្នោះដែរ។

## គុណរបស់ភោគៈ

ភោគៈ ដែលបណ្ដាលឲ្យកើតទៅជាគុណនោះ គឺភោគៈដែលនៅក្នុងកណ្ដាប់ដៃមនុស្សអ្នកមានប្រាជ្ញាល្អ ក្នុងទីនេះសម្ដៅយកមនុស្សមិនកំណាញ់ ឬមនុស្សមិនបណ្ដោយចិត្តឲ្យភោគៈរួបរឹតសម្លាប់ខ្លួនឯងវិញទេ គេអាចយកភោគៈនោះទៅលៃលកចាត់ចែងធ្វើឲ្យកើតទៅជាគុណ ទៅជាប្រយោជន៍ច្រើនយ៉ាងដល់ខ្លួននិងដល់អ្នកដទៃទូទៅ ដូចការចិញ្ចឹមទំនុកបម្រុងមាតាបិតា បុត្រភរិយា បងប្អូន បាវព្រាវឲ្យជាសុខ ជួយសង្គ្រោះទំនុកបម្រុងសមណបព្វជិត ពួកញាតិមិត្រនិងស្មូមយាចក អ្នកកម្សត់ទុគ៌តឲ្យជាសុខ កសាងគ្រឹះស្ថានសិក្សាវិជ្ជាទាំងផ្លូវលោក ផ្លូវធម៌ កសាងអាវាសជាលំនៅនៃព្រះសង្ឃ មានឧបដ្ឋានសាលា វិហារជាដើម កសាងអាវសថសាលា គឺសាលាសម្រាប់ស្នាក់អាស្រ័យនៃអ្នកដំណើរគ្រប់ប្រភេទតាមផ្លូវធំតូចធំ កសាងស្ពាន ផ្លូវថ្នល់ មន្ទីរ

ពេទ្យប៉ុណ្ណោះជាដើម ឲ្យគេបានទទួលសេចក្ដីសុខដោយសារភោគៈរបស់ខ្លួន។ មនុស្សអ្នកមានប្រាជ្ញាល្អ រមែងយកភោគៈទៅប្រើការផ្សេងៗ ដូចបានពោលមកហើយ ឲ្យទៅជារបស់សាធារណៈមានប្រយោជន៍ ចែកសេចក្ដីសុខដល់អ្នកដទៃ តួយ៉ាងដូចព្រះពុទ្ធជាបរមគ្រូនៃយើងជាដើម កាលដែលព្រះអង្គនៅក្នុងឋានៈជាពោធិសត្វ ទ្រង់សោយព្រះជាតិជាវេស្សន្តរជាដើម ព្រះអង្គបានឃើញប្រយោជន៍ដ៏ធំទូលាយ ទ្រង់មិនមានព្រះទ័យជាប់នឹងភោគៈទេ ទ្រង់យកភោគៈរបស់ព្រះអង្គចែករំលែកជាទានសង្គ្រោះឲ្យគេបានសុខ រហូតដល់បុត្រភរិយាសោតទៀត ក៏ព្រះអង្គធ្វើឲ្យទៅជាទានដែរ ប៉ុន្តែទានរបស់ព្រះអង្គដែលធ្វើទាំងប៉ុន្មាន សុទ្ធតែជាបារមិតាទានទាំងអស់។ ពុំនោះសោតដូចព្រះឥន្ទ្រាធិរាជ កាលនៅជាមនុស្សមានឈ្មោះថា មឃមាណព បានធ្វើអាវាសថសាលា ជីកស្រះ ដាំដើមឈើ ធ្វើសួនច្បារផ្កា ឲ្យជាទានសម្រាប់អ្នកដំណើរទាំងពួងចូលជ្រកស្នាក់អាស្រ័យកម្សាន្តសប្បាយ។ មឃមាណព ដែលធ្វើយ៉ាងនេះឈ្មោះថាជាអ្នកធ្វើប្រយោជន៍ជាសាធារណៈដើម្បីឲ្យអ្នកដទៃបានទទួលសេចក្ដីសុខស្រួលដោយសារតែភោគៈរបស់ខ្លួនដែរ។ ព្រោះហេតុនោះ បុគ្គលអ្នកមានភោគៈ គួរតែចែករំលែកលះប្រយោជន៍តិច ហើយប្ដូរយកប្រយោជន៍ច្រើនឬលះសុខបន្តិចបន្តួចហើយប្ដូរយកសុខដ៏ធំទូលាយ សមដូចពុទ្ធដីកាថាៈ

មត្តា សុខបរិច្ចាគា　　បស្សេ ចេ វិបុលំ សុខំ
ចជេ មត្តាសុខំ ធីរោ　　សម្បស្សំ វិបុលំ សុខំ។

បើបុគ្គលឃើញសុខដ៏ធំទូលាយ គួរតែលះសុខបន្តិចបន្តួចចេញ ៦

បុគ្គលអ្នកមានប្រាជ្ញា កាលបើឃើញច្បាស់នូវសុខដ៏ធំទូលាយហើយ តែងតែលះបង់នូវសុខបន្តិចបន្តួចចេញ។

ពាក្យថាសុខបន្តិចបន្តួច គឺសុខផ្ទាល់ខ្លួនឬសុខក្នុងគ្រួសាររបស់ខ្លួនឬក៏សុខរបស់មនុស្សលោកនេះ ឯសុខដ៏ធំទូលាយ គឺសុខក្នុងទិព្វសម្បត្តិ ជាពិសេសបំផុត គឺសុខក្នុងនិព្វានសម្បត្តិ ឈ្មោះថាសុខជាស្ថាពរ ជាសុខទៀងទាត់ ឥតមានវិបរិតប្រែប្រួលឡើយ។

ម្យ៉ាងទៀត ភោគៈនេះជារបស់សំខាន់ អាចផ្តល់គុណប្រយោជន៍គ្រប់យ៉ាងឲ្យតាមសេចក្តីប្រាថ្នារបស់មនុស្សទូទៅក៏ពិតមែន ប៉ុន្តែមនុស្សអ្នកមានគំនិតយល់ត្រូវ រមែងមិនបណ្តោយចិត្តឲ្យជាប់ជំពាក់ក្នុងភោគៈទេ មិនធ្វើឲ្យខ្លួនបានទុក្ខទោសគ្រោះថ្នាក់ក្នុងបច្ចុប្បន្ននេះឬក្នុងបរលោក ពីព្រោះតែភោគៈទេ គេចេះលៃលកយកភោគៈធ្វើជាយានជំនិះ ឆ្លងផុតពីទុក្ខគ្រប់យ៉ាងទៅកាន់បរមសុខ គឺនិព្វានបាន ដូចមនុស្សទាំងឡាយក្នុងសម័យពុទ្ធកាល មានអនាថ-បិណ្ឌិកសេដ្ឋីនិងនាងវិសាខាជាដើម សុទ្ធតែជាអ្នកមានសទ្ធាដ៏មាំ ទាំងភោគៈសម្បត្តិក៏ច្រើនផង។ អនាថបិណ្ឌិកសេដ្ឋី បានសាងវត្តមួយហៅថា វត្តជេតពន ចំណែកនាងវិសាខាបានសាងវត្តមួយ ហៅថាវត្តបុព្វារាម។ មិនត្រឹមតែប៉ុណ្ណោះទេ ជនទាំងពីនាក់នេះ បានបរិច្ចាគទ្រព្យជាទានចំពោះប្រយោជន៍ជាសាធារណៈដទៃទៀតក៏ច្រើន ព្រោះហេតុនេះ បានជាព្រះសម្ពុទ្ធបរមគ្រូ ទ្រង់ត្រាស់សរ-សើរចំពោះអនាថបិណ្ឌិកនិងនាងវិសាខា ថាជាអគ្គសាសនូបត្ថម្ភក៍ ក្នុងព្រះពុទ្ធសាសនា ដោយព្រះពុទ្ធដីកាថាៈ

យថាបិ បុប្ផរាសិម្ហា កយិរា មាលាគុណេ ពហូ
ឯវំ ជាតេន មច្ចេន កត្តព្វំ កុសលំ ពហុំ។

នាយមាលាការ ចេះធ្វើកម្រងផ្កាបានច្រើនអំពីគំនរនៃផ្កា យ៉ាងណាមិញ សត្វដែលកើតមក (ក្នុងលោក) គួរតែធ្វើកុសលឲ្យបានច្រើន (អំពីគំនរនៃភោគៈ) ក៏ដូច្នោះដែរ។

អធិប្បាយថា នាយមាលាការយកផ្កាផ្សេងៗ អំពីគំនរផ្កាមករចនាក្រងធ្វើឲ្យទៅជាកម្រងផ្កាមានរូបភាពបានច្រើនបែប ច្រើនយ៉ាង គួរជាទីរមិលមើល គួរជាទីជ្រះថ្លាចាប់ចិត្តយ៉ាងក្រៃលែង ដល់អ្នកទៃដែលត្រូវការ យ៉ាងណាមិញ នរជនដែលកើតមកក្នុងលោក គួរតែលៃលកយកភោគៈបំពេញកុសលផ្សេងៗឲ្យបានច្រើនបែប ច្រើនយ៉ាង ទាំងខាងផ្លូវលោក ទាំងផ្លូវធមិ ដើម្បីជាប្រយោជន៍សាធារណៈដល់អ្នកដទៃដែលត្រូវការ ក៏ដូច្នោះដែរ ប៉ុន្តែបើទុកជានាយមាលាការ ជាអ្នកឈ្លាសប៉ិនប្រសប់ យ៉ាងណាក៏ដោយ បើផ្កាមានចំនួនតិច ក៏មិនអាចលៃលកក្រងកម្រងផ្កាឲ្យបានច្រើនបែបដែរ។ ចំណែកខាងនាយមាលាការ ជាអ្នកមិនឈ្លាស មិនប៉ិនប្រសប់ ទោះបីមានផ្កាតិចក្តី ច្រើនក្តី ក៏រឹតតែមិនអាចធ្វើកម្រងផ្កាឲ្យច្រើនបែបបានឡើយ ឯនាយមាលាការដែលឈ្លាស ប៉ិនប្រសប់ កាលបើផ្កាមានច្រើន ក៏អាចលៃលកធ្វើកម្រងផ្កាឲ្យមានបែបភាពច្រើនយ៉ាងទៅបាន យ៉ាងណាមិញ មនុស្សខ្លះមានសទ្ធាតិចទន់ខ្សោយតែភោគៈមានច្រើន ក៏មិនអាចធ្វើកុសលឲ្យច្រើនយ៉ាងបានដែរឬបើមានសទ្ធាតិចទន់ខ្សោយ ទាំងភោគៈក៏មានតិចតួចផងដែរ ក៏រឹតតែមិនអាចធ្វើ

កុសលឲ្យច្រើនបានឡើយ បើសទ្ធាមានកម្លាំងលើសលប់ ប៉ុន្តែភោគៈមានតិចស្តួចស្តើង ក៏មិនអាចធ្វើកុសលឲ្យបានច្រើនដែរ លុះតែសទ្ធាក៏មានកម្លាំងលើសលប់ផង ទាំងភោគៈក៏មានច្រើនលើសលប់ផង ទើបអាចចាត់ចែងធ្វើកុសលឲ្យច្រើនយ៉ាងទៅបាន ក៏ដូច្នោះដែរ ព្រោះហេតុនោះ បុគ្គលអ្នកបរិបូណ៌ដោយសទ្ធា ទាំងបរិបូណ៌ដោយភោគៈផង គួរតែបញ្ចេញសកម្មភាពរបស់ខ្លួនឲ្យបានរឹងប៉ឹង ជួយឧបត្ថម្ភរុញចក្រទាំង២ គឺពុទ្ធចក្រនិងអាណាចក្រឲ្យបានលឿនឆ្ពោះទៅកាន់វឌ្ឍនភាពគ្រប់យ៉ាង ទើបឈ្មោះថា ជាអ្នកចេះរចនាលៃលកធ្វើភោគៈជារបស់ឥតខ្លឹមសារ ឲ្យទៅជារបស់មានខ្លឹមសារ ជារបស់មានប្រយោជន៍តិច ឲ្យទៅជារបស់មានប្រយោជន៍ច្រើន ជារបស់មានសុខតិត ឲ្យទៅជារបស់មានសុខច្រើន។

ពិតណាស់ភោគៈនេះ បើបុគ្គលមានគំនិតល្អ ចេះលៃលកចាត់ចែងឲ្យប្រព្រឹត្តទៅក្នុងផ្លូវដែលត្រូវល្អហើយ រមែងនាំឲ្យទៅជាគុណប្រយោជន៍យ៉ាងក្រៃលែង នឹងរាប់ នឹងប្រមាណពុំបានឡើយ ទាំងកិត្តិសព្ទ គឺកេរ្តិ៍ឈ្មោះសោតទៀត ក៏ភ្លឺរុងរឿងចញ្ចែងចិញ្ចាចមិនរលត់សូន្យឈឹង សមនឹងសុភាសិតបុរាណថា "ភ្លឺពីមនុស្សលោករួចដល់សួគ៌ិនាយ" ទាំងពុទ្ធសភាសិត ក៏មានសម្តែងបញ្ជាក់ថា "រូបគឺរាងកាយរបស់សត្វទាំងឡាយ មិនចេះទ្រុឌទ្រោមបាត់បង់ទៅណាឡើយ"។

## ទោសរបស់ភោគៈ

ភោគៈដែលបណ្តាលឲ្យកើតទៅជាទោសនោះ គឺភោគៈដែលនៅក្នុង

កណ្ដាប់ដៃនៃមនុស្សកំណាញ់។ មនុស្សកំណាញ់តែងបណ្ដោយចិត្ត ឲ្យភោគៈ រួបរឹតសម្លាប់ខ្លួនឯងវិញ មិនយកភោគៈទៅចាត់ចែងក្នុងការកុសលណាមួយ ដែលជាប្រយោជន៍សាធារណៈ ចែកសេចក្ដីសុខដល់អ្នកដទៃឬភោគៈដែល នៅក្នុងកណ្ដាប់ដៃនៃមនុស្សឥតប្រាជ្ញា។ មនុស្សឥតប្រាជ្ញាតែងយកភោគៈទៅ ប្រើប្រាស់ចាយវាយក្នុងផ្លូវអកុសល ដែលជាហេតុនាំឲ្យកើតទុក្ខគ្រប់យ៉ាង ដល់ខ្លួនឯងវិញ ទាំងក្នុងបច្ចុប្បន្ននិងបរលោក ពីព្រោះតែភោគៈ ដូចសេដ្ឋីបុត្រ ទាំង៤នាក់ ក្នុងគម្ពីរធម្មបទមានសេចក្ដីសម្ដែងថា សេដ្ឋីបុត្រទាំង៤នាក់នោះ គិតគ្នាថា យើងមានសម្បត្តិច្រើនតើយើងធ្វើយ៉ាងណាទើបសប្បាយក្នុងលោក នេះ? អ្នកខ្លះថាយើងត្រូវយកទ្រព្យទៅប្រលោមប្រពន្ធកូនអ្នកដទៃ ធម្មតាស្ត្រី គង់នឹងលង់ខ្លួនដោយទ្រព្យយើងពុំខាន អ្នកខ្លះថា យើងត្រូវយកទ្រព្យទៅ ស្វែងរកស្ត្រីដែលមានរូបល្អៗ ជាអ្នកប៉ិនប្រសប់ក្នុងការច្រៀងរាំក្នុងសម្នាក់ យើង អ្នកខ្លះថា យើងត្រូវបរិភោគអាហារឆ្ងាញ់ៗ មានសាច់និងសុរាជាដើម អ្នកខ្លះថា យើងត្រូវតែប្រកបល្បែងច្រៀងរាំ ដែលនាំឲ្យសប្បាយជានិច្ចតទៅ យ៉ាងនេះជាដើម ត្រង់គំនិតគិតថា យើងនឹងធ្វើការកុសលនេះខ្លះ ទុកជាប្រ-យោជន៍ខ្លួនឬជាប្រយោជន៍សាធារណៈសូម្បីបន្តិចបន្តួចក៏គ្មានសោះឡើយ។

ដោយអំណាចនៃការនាំគ្នាប្រព្រឹត្តអបាយមុខយ៉ាងនេះ សេដ្ឋីបុត្រទាំង ៤នាក់នោះ លុះអស់ជីវិតទៅក៏ធ្លាក់ទៅរងទុក្ខក្នុងអបាយភូមិ ពីព្រោះតែងយក ភោគៈទៅប្រើប្រាស់ក្នុងផ្លូវអកុសល។

ភោគៈ រមែងសម្លាប់បុគ្គលឥតប្រាជ្ញា ដូចបានពណ៌នាមកនេះឯង

ព្រោះហេតុនោះបានជាព្រះសព្វញ្ញុពុទ្ធទ្រង់ត្រាស់ថា ៖

ផលំ វេ កទលឹ ហន្តិ ផលំ វេឡុំ ផលំ នឡំ

សក្ការោ កាបុរិសំ ហន្តិ គព្ភោ អស្សតរឹ យថា។

សេចក្តីថា ផ្លែចេក តែងសម្លាប់នូវដើមចេក ផ្លែឫស្សី តែងសម្លាប់នូវដើមឫស្សី ផ្លែបបុស តែងសម្លាប់នូវដើមបបុស, សក្ការៈ តែងសម្លាប់នូវបុរសអាក្រក់ គឺបុរសដែលមានគំនិតទុច្ចរិតលាមក ដូចជាគភ៌នៃសេះអស្សតរ តែងសម្លាប់នូវមេសេះដូច្នោះដែរ។

អធិប្បាយថា ធម្មតាដើមចេកក្តី ដើមឫស្សីក្តី ដើមបបុសក្តី កាលណាបើចេញផ្លែមក តែងតែសម្លាប់ដើមឯង ចំណែកខាងសក្ការៈ គឺទ្រព្យសម្បត្តិទាំងពួងកើតឡើងដល់បុរសបុគ្គលណា ដែលល្ងង់ឥតប្រាជ្ញា មានគំនិងអាក្រក់តែងសម្លាប់នូវបុរសបុគ្គលនោះវិញ ដូចគ្នានឹងដើមចេក ដើមឫស្សីនិងដើមបបុសដូច្នោះដែរ។ ភោគៈគេតែងចំណាយប្តូរយកសេចក្តីសុខគ្រប់យ៉ាង ក្នុងបច្ចុប្បន្ននិងបរលោក រហូតដល់សុខព្រះនិព្វានទៀត។ មនុស្សល្ងង់ឥតប្រាជ្ញាមិនស្គាល់ហេតុផល ត្រឡប់ជាចំណាយប្តូរយកសេចក្តីទុក្ខភ័យអន្តរាយគ្រប់យ៉ាងមកប្រគល់ខ្លួនឯងវិញ ទាំងក្នុងបច្ចុប្បន្ននិងបរលោក។ បើពុទ្ធសាសនិកអ្នកមានវិចារណញ្ញាណដ៏ជ្រាលជ្រៅ បានពិចារណាដោយល្អិតហ្មត់ចត់ទៅ ក៏គង់ឃើញច្បាស់ចំពោះមនុស្សខ្លះ ក្នុងបច្ចុប្បន្ននេះក៏មាននិងមនុស្សខ្លះ ក្នុងអតីតក៏មាន ដូចតោទេយ្យព្រាហ្មណ៍ ស្លាប់ទៅកើតជាឆ្កែ ពីព្រោះតែភោគៈ, អានន្ទសេដ្ឋី ស្លាប់ទៅកើតក្នុងត្រកូលចណ្ឌាលជាជាតិថោកទាប មានរាងកាយ

ពិការអាក្រក់ដូចជាបិសាច គេធ្វើបាបវាយសន្លប់បាត់ស្មារតី ហើយលើកបោះទៅលើគំនរសម្រាប់ ពីព្រោះតែភោគៈជាមូលហេតុ។

សេចក្តីដែលបានបរិយាយមកនេះហាក់ដូចជានាំគ្នាឲ្យស្អប់ភោគៈឬកុំឲ្យស្វែងរកភោគៈ មិនមែនដូច្នោះទេ។ ភោគៈ ជាជីវភាពដ៏ថ្លៃថ្នូររបស់មនុស្សទូទៅ គេត្រូវតែស្រឡាញ់ ត្រូវតែស្វែងរក ត្រូវតែចង់បាន ប៉ុន្តែគេស្វែងរកដោយត្រូវទំនងក្នុងផ្លូវសុចរិត កាលបើបានភោគៈនោះមកហើយ គេត្រូវលៃលកទុកដាក់ឬចំណាយទៅវិញក៏ឲ្យត្រូវទំនងប្រកបដោយសុចរិតដែរ។ បើស្វែងរកដោយផ្លូវទុច្ចរិតក្តី បានមកហើយចំណាយទៅវិញដោយផ្លូវទុច្ចរិតក្តី ភោគៈនោះឯង រមែងក្លាយទៅជាទោសសម្លាប់បុគ្គលនោះវិញ គឺធ្វើឲ្យដល់នូវសេចក្តីវិនាសច្រើនយ៉ាង សមដូចជាពុទ្ធភាសិតថាៈ

ភោគតណ្ហាយ ទុម្មេធោ ហន្តិ អញ្ញេវ អត្តនំ

បុគ្គលឥតប្រាជ្ញា រមែងសម្លាប់ខ្លួនឯង ដូចជាសម្លាប់អ្នកដទៃ ព្រោះតែការចង់បានភោគៈ។ ពាក្យថាបុគ្គលឥតប្រាជ្ញា បានដល់មនុស្សមិនស្គាល់ហេតុផល ដែលប្រកបដោយលោភៈ មោហៈ មានះ មានការលោភលន់ចង់បានហួសប្រមាណ មិនដឹងការល្អអាក្រក់ ខ្ពស់ទាប សម្គាល់ថាខ្លួនគ្រាន់បើលើសគេជាដរាប។ ពាក្យថា សម្លាប់ខ្លួនឯងចោល គួរជ្រាបសេចក្តីថា គឺទម្លាយនូវគុណធម៌ សេចក្តីល្អរបស់ខ្លួនឯងចោល ដូចមនុស្សអ្នកមានកិត្តិសព្ទកេរ្តិ៍ឈ្មោះ មានយសស័ក្តិ កាលបើសេចក្តីចង់បានក្នុងភោគៈ មានកម្លាំងកើតឡើងច្រើនប្រកបដោយលោភៈ មោហៈ មានះ កាលធ្វើខ្លួនឲ្យលង់ក្នុងអំណាច

នៃកិលេសទាំងនេះហើយ ឯកិត្តិសព្ទ កេរ្តិ៍ឈ្មោះដែលធ្លាប់ក្រអូប ក៏ត្រឡប់ទៅជាស្អុយ, យសស័ក្តិ ដែលធ្លាប់សម្បូណ៌ ក៏ត្រឡប់ទៅជាសូន្យ ដូច្នេះជាដើមនេះឈ្មោះថាសម្លាប់ខ្លួនឯង។

តណ្ហា ប្រែថា សេចក្តីចង់បាន, ក្នុងទីនេះសម្តៅយកសេចក្តីចង់បានភោគៈ។ មនុស្សគ្រប់ប្រភេទ សុទ្ធតែមានសេចក្តីចង់បានភោគៈដូចៗគ្នាទាំងអស់។ ព្រោះយល់ថាភោគៈជារបស់អាចញ៉ាំងជីវភាពនៃមនុស្សឲ្យបានថ្លៃថ្នូរគ្រប់យ៉ាង។ ភោគៈនោះបើកើតឡើងដល់បុគ្គលអ្នកមានប្រាជ្ញា ក៏នាំឲ្យបានសេចក្តីសុខចម្រើន តែបើកើតឡើងដល់បុគ្គលឥតប្រាជ្ញា រមែងមានតែនាំឲ្យកើតទោសដល់ខ្លួនវិញ ព្រោះបុគ្គលឥតប្រាជ្ញា ច្រើនស្វែងរកភោគៈ ដោយផ្លូវអកុសល ដូចធ្វើចោរកម្ម សម្លាប់គេ លួចប្លន់គេ កុហកបញ្ឆោតបោកប្រាសគេ គម្រាមកំហែងគេ បំភាន់គំនិតគេដោយឧបាយដើម្បីភោគៈ។ ការស្វែងរកភោគៈដោយផ្លូវអកុសលដូច្នេះ ឈ្មោះថានាំយកនូវទោស គឺទុក្ខភ័យមកប្រគល់ឲ្យដល់ខ្លួនក្នុងបច្ចុប្បន្ននិងអនាគត។

ម្យ៉ាងទៀត មនុស្សកំណាញ់ក៏ជាទោសមួយយ៉ាងធំណាស់ដែរ ដែលអ្នកប្រាជ្ញាគួរតិះដៀល។ ដែលហៅថា មនុស្សកំណាញ់ គឺអ្នកដែលហួងហែងទ្រព្យសម្បត្តិទុកមិនឲ្យខ្ចាត់ខ្ចាយចេញ សូម្បីខ្លួនឯងក៏មិនហ៊ានយកប្រើប្រាស់ទាំងអ្នកដទៃក៏មិនចែករំលែកឲ្យ, ស្វែងរកទ្រព្យសម្បត្តិបានមក គ្រាន់តែសន្សំទុកដាក់ឲ្យគង់នៅតែម្យ៉ាងប៉ុណ្ណោះ ឥតបានទទួលផលអ្វីអំពីទ្រព្យសម្បត្តិនោះឡើយ។ ការសន្សំទ្រព្យសម្បត្តិទុករបស់មនុស្សកំណាញ់ ប្រហែលគ្នានឹងការ

សន្សំដុំឥដ្ឋ ដុំថ្ម ទុកដែរ នាំឲ្យតែរឿតផ្ទះឥតប្រយោជន៍។ ដោយអំណាចសេចក្តីកំណាញ់ហួងហែងទ្រព្យសម្បត្តិទុកនោះឯង លុះដល់ទីបំផុតនៃជីវិត ក៏រមែងទទួលនូវទោសដ៏ធំគួរឲ្យខ្លាច ដូចតោទេយ្យព្រាហ្មណ៍ ស្លាប់ទៅកើតជាឆ្កែ ពីព្រោះតែកំណាញ់, អានន្ទសេដ្ឋី ស្លាប់ទៅកើតជាមនុស្សថោកទាបមានរូបអាក្រក់ ពីព្រោះកំណាញ់, កោសិយសេដ្ឋីនិងមច្ឆរិយសេដ្ឋី មានសម្បត្តិគរគោកហើយប្រើប្រាស់មិនកើត ពីព្រោះតែកំណាញ់។ មនុស្សក្នុងបច្ចុប្បន្ននេះក៏មានខ្លះដែរ អ្នកខ្លះស្លាប់ទៅកើតជាពស់ក៏មាន ទៅកើតជាតុកកែក៏មាន ទៅកើតជាកង្កែបក៏មាន ពីព្រោះតែកំណាញ់ក្នុងភោគៈនោះឯងជាមូលហេតុ។

ម្យ៉ាងវិញទៀត ធម៌៣យ៉ាងគឺ លាភ យស ស័ក្តិ។ លាភ គឺ ភោគសម្បទគ្រប់យ៉ាងដូចបានពោលមកហើយ, យស គឺមនុស្សជាបរិវារ គ្នីគ្នា, ស័ក្តិ គឺឋានន្តរឬងារ។ លាភ យស ស័ក្តិ ទាំង៣នេះជាឥដ្ឋារម្មណ៍ជាទីប្រាថ្នាឬជាទីត្រូវការក្រៃលែងរបស់មនុស្សក្នុងលោក ដូចជាថ្នាំពិសសម្រាប់បំពុលមនុស្សឲ្យវង្វេងឬដូចជារបស់អ្វីពិសេស សម្រាប់បំប៉ោងទឹកចិត្តមនុស្សឲ្យប៉ោងខ្ពស់ឡើង សម្តែងអាការខុសពីប្រក្រតី ជាហេតុឲ្យអ្នកដទៃសង្កេតឃើញបានដោយងាយ ដូចអ្នកខ្លះបានលាភគ្រប់គ្រាន់ហើយ ចង់បានយសទៀត បានយសហើយ ចង់បានស័ក្តិទៀត បានស័ក្តិហើយ ក៏កើតអស្មិមានះសម្គាល់ថាគេពុំត្រឹមស្មើរនឹងខ្លួន។ ពុំនោះសោត អ្នកខ្លះបានស័ក្តិហើយ ចង់បានយសទៀត. បានយសហើយ ចង់បានលាភទៀត។ សេចក្តីត្រូវការរបស់មនុស្សក្នុងលោកគ្មានទីបំផុត ព្រោះហេតុនោះបានជាព្រះសម្មាសម្ពុទ្ធបរមគ្រូទ្រង់

សម្ដែងថា "នត្ថិ តណ្ហា សមា នទី មេទឹក គឺទន្លេឬស្ទឹងជាដើម មិនស្មើដោយតណ្ហាទេ" បានសេចក្ដីថា ទឹកទន្លេឬស្ទឹង មានវេលាពេញដោរ មាននាច មានស្រក មានរីងស្ងួតម្ដងៗ ឯតណ្ហាសេចក្ដីត្រូវការរបស់មនុស្សគ្មានវេលានាច ស្រកឬរីងស្ងួតទេ មានតែវេលាពេញដោរជាធម្មតា។

មែនពិត លាភ យស ស័ក្តិ នេះបើកើតឡើងដល់បុគ្គលណាដែលឥតប្រាជ្ញា រមែងញ៉ាំងទឹកចិត្តនៃបុគ្គលនោះ ឲ្យរំភើបញាប់ញ័រ ឲ្យវង្វេងសម្ដែងអាការខុសប្រក្រតីរហូតដល់ហ៊ានប្រព្រឹត្តធ្វើនូវអំពើលាមកដោយឥតកោតញញើត ដូចទេវទត្ត ហ៊ានប្រទូស្តចំពោះព្រះសម្មាសម្ពុទ្ធ ដរាបទទួលនូវបាបកម្មជាទម្ងន់ត្រូវព្រះធរណីស្រូប ពីព្រោះតែ លាភ យស ស័ក្តិ, ព្រះបាទអជាតសត្រូវ ហ៊ានប្រព្រឹតធ្វើឃាតកម្ម ចំពោះព្រះបាទពិម្ពិសារជាព្រះបិតាដរាបទទួលទុក្ខក្នុងមហានរក ពីព្រោះតែ លាភ យស ស័ក្តិ ហ្នឹងឯងជាមូលហេតុ។

ព្រោះហេតុនោះ អស់លោក-អ្នកពុទ្ធសាសនិកទាំងឡាយ អ្នកប្រាថ្នាសេចក្ដីសុខដើម្បីខ្លួន កាលបើឥដ្ឋារម្មណ៍ទាំង៣គឺ លាភ យស ស័ក្តិ ណាមួយកើតឡើងដល់ខ្លួនហើយគួរហើយ គួរតែប្រុងប្រយ័ត្នស្មារតីកុំឲ្យអភិជ្ឈានិងទោមនស្សកើតឡើង ញ៉ាំញីចិត្តទាញទម្លាក់ទៅរកផ្លូវអកុសលបានឡើយ។

ស្រាវជ្រាវដោយៈ ជាច់ សុគីម